សម្លេងខ្មែរនៅបរទេស

# ការវិភាគ

## របស់ព្រះតេជព្រះគុណបណ្ឌិត ហុក-សាវណ្ណ
## ក្រោមប្រធានបទ បុគ្គលធ្វើឲ្យអ្នកដទៃមានទុក្ខ តែងជាប់ជំពាក់ពៀរ

www.hoksavann.org

ថ្ងៃទី១១ មិថុនា ២០១៣



គាថាថា បុគ្គលណាប្រាថ្នាសេចក្តីសុខដើម្បីខ្លួន ដោយការធ្វើសេចក្តីទុក្ខឲ្យកើតមានដល់អ្នកដទៃ បុគ្គលនោះតែងជាប់ជំពាក់ដោយគ្រឿងជាប់ជំពាក់គឺ **ពៀរ** នឹងមិនរួចផុតអំពីពៀរវេរានេះ ចេញពីបាលីថា **បរទុក្ខូបធានេនយោ អត្តនោ សុខមិច្ឆតិ វេរសំសគ្គ សំសង្គោ វេរា សោ ន បរិមុច្ចតិ** ។ គាថានេះមានសេចក្តីថា មនុស្សគ្រប់រូបតែងតែប្រាថ្នាសេចក្តីសុខ ដើម្បីខ្លួនចង់រស់នៅប្រកបដោយសេចក្តីចំរើនរុងរឿងដូចគ្នា ។ ប៉ុន្តែមនុស្សខ្លះចង់បានសុខខ្លួនឯង បែរទៅជាបៀតបៀនអ្នកដទៃដែលជាហេតុនាំឲ្យមានទុក្ខដល់ខ្លួនទៅវិញ គឺការប្រព្រឹត្តធ្វើអំពើអាក្រក់ប៉ះពាល់ដល់សេចក្តីសុខរបស់អ្នកដទៃ ។ ព្រះពុទ្ធសំដែងថា មនុស្សកើតមកត្រូវបំពេញការងារ ប៉ុន្តែការងារដែលត្រឹមត្រូវ ការងារដែលមិនមានទោស ការងារដែលមិនធ្វើឲ្យអ្នកដទៃមានសេចក្តីទុក្ខព្រួយ ភ័យខ្លាច ឬធ្វើឲ្យវិនាស ប៉ុន្តែត្រូវបំពេញការងារប្រកបដោយសុចរិត ដែលហៅថា **សម្មាអាជីវោ** ប្រែថាការងារដ៏ប្រពៃ ។ ខាងចុងនៃគាថានេះបញ្ជាក់ថា បើបុគ្គលបៀតបៀនធ្វើឲ្យគេមានទុក្ខ បុគ្គលនោះតែងទទួលផលបាបធ្វើឲ្យខ្លួនមានទុក្ខវិញ តាមកម្រិតអកុសលដែលខ្លួនបានប្រព្រឹត្ត ។ ពាក្យថា **ពៀរ** គឺផលនៃអំពើបាបនេះឯង ។ ប៉ុន្តែពៀរម៉្យាងទៀត សំដៅយកការចងកំហឹងនឹងគ្នា ពីជាតិនេះរហូតដល់ជាតិខាងមុខទៀត ។

អំពើដែលធ្វើឲ្យគេមានទុក្ខមានប្រភេទច្រើនយ៉ាងមានបុគ្គលខ្លះក្នុងលោកនេះចង់បានទ្រព្យសម្បត្តិអ្នកដទៃក៏ប្រព្រឹត្តការលួច ឆក់ ប្លន់ បើអ្នករដ្ឋការប្រព្រឹត្តអំពើពុករលួយ មានអ្នកលួច ឬប្លន់ខ្លះ ហ៊ានរហូតដល់សម្លាប់ម្ចាស់ទ្រព្យថែមទៀត ។ ធ្វើឲ្យគេមានទុក្ខ គឺធ្វើឲ្យគេអស់ទ្រព្យសម្បត្តិ ហើយមានម្ចាស់ទ្រព្យខ្លះត្រូវបាត់បង់ជីវិតថែមទៀត ។ ការលួចប្រពន្ធកូនអ្នកដទៃដើម្បីបំពេញតណ្ហារបស់ខ្លួន នេះជាការប៉ះពាល់ដល់សេចក្តីសុខអ្នកដទៃ ដែលគេចង់ជួបជុំប្តីប្រពន្ធកូនចៅ មិនចង់បែកបាក់គ្នាដូចខ្លួនអ្នកប្រព្រឹត្តអាក្រក់នោះដែរ ។ បើអ្នកនយោបាយវិញ លួចសម្លាប់គ្នាដើម្បីបំពេញបំណងរបស់ខ្លួន ដែលធ្វើឲ្យគ្រួសារគេព្រាត់ប្រាស់គ្នា ហើយធ្វើឲ្យជាតិមានអសន្តិសុខផង ។ បើអ្នករដ្ឋការប្រព្រឹត្តអំពើពុករលួយ ស៊ីសំណូក ធ្វើឲ្យសេដ្ឋកិច្ចជាតិចុះទន់ខ្សោយ ធ្វើឲ្យប្រជាពលរដ្ឋមានភាពក្រីក្រ ។ បើក្នុងប្រទេសកើតសង្គ្រាមនឹងគ្នាវិញ នឹងធ្វើឲ្យប្រជាពលរដ្ឋស្លាប់ព្រាត់ប្រាស់គ្នា ពិការបាក់ដៃបាក់ជើង នេះជាសេចក្តីទុក្ខដែលបង្កឡើងដោយបុគ្គលបាប ។

អ្នកសាងបាបកម្មដោយការលួចប្លន់ទ្រព្យសម្បត្តិអ្នកដទៃ ឬរបស់ជាតិ បើគេចាប់បាននឹងទទួលទោសទណ្ឌកម្មក្នុងបច្ចុប្បន្ន បើគេចាប់ពុំបានទេ ក៏គេចពុំផុតអំពីទោសទៅមុខទៀតដែរ ។ ក្នុងសុត្តន្តបិដកនិយាយថា អ្នកដែលលួចទ្រព្យសម្បត្តិអ្នកដទៃ ស្លាប់ទៅធ្លាក់ទៅសោយទុក្ខក្នុងនរក លុះសេសសល់ផលកម្ម បើបានមកកើតជាមនុស្សវិញ បើមានទ្រព្យសម្បត្តិ ក៏ទុកពុំគង់ ចេះតែវិនាសទៅវិញដោយហេតុផ្សេងៗ ។ បើបុគ្គលសម្លាប់គេ ឬប្រើគេឲ្យសម្លាប់ បើគេចាប់បាននឹងមានទោសទណ្ឌកម្មក្នុងបច្ចុប្បន្នតាមច្បាប់របស់រដ្ឋ ។ លុះបុគ្គលនោះស្លាប់ទៅ នឹងធ្លាក់ទៅសោយទុក្ខក្នុងនរក លុះសេសសល់ផលកម្ម បើបានកើតមកជាសត្វ ឬមនុស្ស ត្រូវគេសម្លាប់ជាច្រើនជាតិ មានអាយុខ្លីដោយទោសនៃការសម្លាប់គេពីជាតិមុន ។ ដូច្នេះតាមអត្ថន័យនៃពុទ្ធភាសិតខាងលើនេះបញ្ជាក់ថា បើបុគ្គលចង់បានសេចក្តីសុខដល់ខ្លួន មិនត្រូវបៀតបៀនមនុស្សសត្វដទៃឡើយ ផ្ទុយទៅវិញត្រូវសាងអំពើល្អនេះឯង សមដូចពុទ្ធភាសិតមួយបទពោលថា **នត្ថិ សន្តិ បរំ សុខំ** មានន័យថា សេចក្តីសុខកើតពីការស្ងប់ គឺស្ងប់ពុំធ្វើអំពើបាបនេះឯង ។

អំពើល្អនិងអំពើអាក្រក់នេះ ចេញមកពីសកម្មភាពខ្លួនឯង បាលីហៅថា **កម្មស្សកោម្ហិ** ប្រែថា សត្វទាំងឡាយមានកម្មជារបស់ខ្លួន ។ ព្រះពុទ្ធត្រាស់ដឹងច្បាប់កម្មផលថា សេចក្តីសុខទុក្ខចំរើនវិនាស កើតចេញមកពីអំពើរបស់ខ្លួន ។ បានសេចក្តីថា ជីវិតរបស់ខ្លួនប្រព្រឹត្តទៅយ៉ាងណា ស្រេចទៅលើសកម្មភាពល្អអាក្រក់របស់ខ្លួនជាអ្នកចាត់ចែង ។ ពាក្យថា **កម្ម** នេះបើតាមន័យរបស់ភាសាខ្មែរឲ្យន័យថា ការលំបាកឬការរងទុក្ខ ។ តាមន័យពិតកម្មនេះជាឈ្មោះនៃអំពើ ជាពាក្យកណ្តាលមានទាំងអំពើល្អនិងអាក្រក់ ។ អំពើល្អឲ្យផលជាសុខ អំពើអាក្រក់ឲ្យផលជាទុក្ខ ។ ប៉ុន្តែបើនិយាយឲ្យដល់ជំរៅព្រះពុទ្ធសាសនា ពាក្យខ្មែរថាកម្មដែលមានន័យថាទុក្ខនេះ ទៅជាត្រូវទៅវិញព្រោះកម្មល្អកម្មអាក្រក់នេះឯង ដែលនាំសត្វឲ្យមានជាតិគឺបដិសន្ធិតទៅទៀត ។ ការមានជាតិ ជាហេតុនាំឲ្យមានទុក្ខ ។

ព្រះពុទ្ធបរមគ្រូត្រាស់ថា ទំនាបនិងកំពស់របស់មនុស្សត្រូវស្ថិតនៅលើអំពើរបស់គេ ដែលហៅថាកម្មនេះឯង ពុំមែនស្ថិតនៅលើក្រមាន មានយសស័ក្តិឥតយសស័ក្តិឡើយ ។ បានសេចក្តីថា មនុស្សឧត្តមប្រសើរនិងមនុស្សថោកទាប ពុំមែនយកជាតិត្រកូល ទ្រព្យសម្បត្តិ យសស័ក្តិធ្វើជាខ្នាតសំរាប់វាស់ឡើយ ។ ស្ទើរតែគ្រប់ទំព័រនៃគម្ពីរព្រះត្រៃបិដក ដែលជាគម្ពីរដ៏ធំរបស់ព្រះពុទ្ធសាសនា ព្រះអង្គបានយកកម្មផលនេះមកធ្វើជាខ្នាត ។ ព្រះសមណគោត្តមជាគ្រូនៃទេវតានិងមនុស្សទាំងឡាយបានពន្យល់ថា បើអ្នកនោះមានជាតិត្រកូលខ្ពស់ មានទ្រព្យសម្បត្តិច្រើន មានអំណាចបុណ្យស័ក្តិធំ តែជាអ្នកប្រព្រឹត្តអំពើអាក្រក់ដោយកាយវាចានិងដោយចិត្ត អ្នកនោះចាត់ថាជាមនុស្សថោកទាប ។ ផ្ទុយទៅវិញ អ្នកនោះគ្មានវិជ្ជាជ្រៅជ្រះនឹងគេទេ ប៉ុន្តែជាអ្នកប្រព្រឹត្តអំពើល្អ លោកចាត់ទុកថា ជាមនុស្សខ្ពង់ខ្ពស់ថ្លៃថ្នូរ ។ បើអ្នកនោះមានវិជ្ជាខ្ពង់ខ្ពស់ ហើយប្រព្រឹត្តល្អទៀត ទើបជាមនុស្សខ្ពង់ខ្ពស់ ។ ដូច្នេះមនុស្សមានលក្ខណៈខុសគ្នា ដោយសារអំពើរបស់គេមានលក្ខណៈ

ខុសគ្នា ។ ព្រះពុទ្ធបានចែកមនុស្សជាច្រើនប្រភេទ ទៅតាមអំពើដែលបានប្រព្រឹត្ត ។ **មនុស្សោ** ជាមនុស្សពេញលក្ខណៈ គឺជាមនុស្សមានចិត្តធម៌ក្នុងខ្លួន ដោយហោចណាស់មានសីល៥ ។ **មនុស្សបេតោ** មនុស្សដូចជាប្រេត គឺមនុស្សមានទ្រព្យសម្បត្តិតែកំណាញ់ស្វិតស្វាញ ។ **មនុស្សតិរច្ឆានោ** មនុស្សដូចសត្វ គឺមនុស្សមិនស្គាល់គុណ ។ **មនុស្សនេរយិកោ** មនុស្សដូចសត្វនរក គឺមនុស្សរំលោភសិទ្ធិអ្នកដទៃ ធ្វើបាបកាប់សម្លាប់អ្នកដទៃ ។ ដូច្នេះ **កម្មផល** តែងបែងចែកមនុស្សសត្វឲ្យខ្ពង់ខ្ពស់និងថោកទាប ដូចពោលមកនេះឯង ។៚

*    *

*